## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៥  ខែ មិនា  ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ៤៣៥,៤៤៩ ដុល្លារអាមេរិក សម្រាប់គម្រោងទ្រង់ទ្រាយតូច សន្តិសុខមនុស្សជាតិចំនួន៤(ផ្នែកសុខាភិបាល)



ឯកឧត្តមគូម៉ាម៉ារ៉ូ យូជិ និងតំណាងស្ថាប័នទទួលជំនួយនិមួយៗ

ក្រោម គ្រោងការណ៍ នៃ កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច របស់ ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៤៣៥,៤៤៩ដុល្លារអាមេរិកដល់ស្ថាប័នទទួលជំនួយចំនួន៤។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងតំណាងស្ថាប័នទទួលជំនួយនិមួយៗដើម្បីអនុវត្តគម្រោងដូចតទៅ៖



អគារវះកាត់បច្ចុប្បន្ន

១. <u>គម្រោងកែលម្អអគារវះកាត់ក្នុងមន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង (១០៩,២១៤ដុល្លារអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ ស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង</u>

ក្នុងគោលបំណងពង្រឹងសមត្ថភាពក្នុងការផ្តល់សេវាសុខាភិបាលជូនអ្នកជំងឺ ស្រុកប្រតិបត្តិពារាំងក្នុងខេត្តព្រៃវែងនឹងធ្វើការកែលម្អអគារវះកាត់មួយ ព្រមទាំងបំពាក់ឧបករណ៍វះកាត់បច្ចេកវិជ្ជាចុងក្រោយក្នុងមន្ទីរពេទ្យបង្អែកពារាំង។

២. <u>គម្រោងបំពាក់ម៉ាស៊ីនជំនួយការដកដង្ហើមក្នុងមន្ទីរពេទ្យកុមារអង្គរ ខេត្តសៀមរាប (១១៤,៣១៤ដុល្លារអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរពេទ្យកុមារអង្គរ</u>



បន្ទប់ជំងឺធ្ងន់

ដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះម៉ាស៊ីនជំនួយការដកដង្ហើមក្នុងបន្ទប់សង្គ្រោះបន្ទាន់និងបន្ទប់ជំងឺធ្ងន់ មន្ទីរពេទ្យកុមារអង្គរនឹងទិញម៉ាស៊ីនជំនួយការដកដង្ហើមទំនើបចំនួន៤គ្រឿងសម្រាប់សង្គ្រោះជីវិតកុមារដែលមានជំងឺធ្ងន់ធ្ងរក្នុងមន្ទីរពេទ្យ។

៣. <u>គម្រោងសាងសង់អគារជំងឺទូទៅ និងកុមារក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាស ខេត្តតាកែវ (១១៦,១២០ដុល្លារអាមេរិក)</u>



អគារជំងឺទូទៅ និងកុមារបច្ចុប្បន្ន

<u>ស្ថាប័នទទួលជំនួយ៖ ស្រុកប្រតិបត្តិព្រៃកប្បាស ខេត្តតាកែវ</u>

ដើម្បីកែលម្អការទទួលបានសេវាថែទាំសុខភាពសម្រាប់ប្រជាជនមូលដ្ឋាន ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃកប្បាស ខេត្តតាកែវ នឹងអនុវត្តគម្រោងសាងសង់អគារជំងឺទូទៅ និងកុមារមួយដែលអាចដាក់គ្រែបាន៤៥ក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាស។ គម្រោងនេះនឹងធ្វើឲ្យប្រជាជនប្រមាណ១៦២,០០០នាក់ដែលរស់នៅក្នុងខេត្តតាកែវអាចទទួលបានសេវាថែទាំសុខភាពដែលមានគុណភាពក្នុងមន្ទីរពេទ្យ។

៤. <u>គម្រោងកែលម្អសុខភាពមាតា និងទារក តាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលក្នុងខេត្តកំពង់ស្ពឺ (៩៥,៨០១ដុល្លាអាមេរិក) ស្ថាប័នទទួលជំនួយ៖ អង្គការកុមារ និងអភិវឌ្ឍន៍</u>


ទីតាំងសាងសង់

ដើម្បីកែលម្អសុខភាពមាតានិងទារកក្នុងខេត្តកំពង់ស្ពឺ អង្គការកុមារ និង អភិវឌ្ឍន៍ នឹងសាងសង់មណ្ឌលសុខភាពមួយនៅក្នុងឃុំចំបក់ និង បន្ទប់រងចាំសម្រាលចំនួន៤ក្នុងមណ្ឌលសុខភាពនៃឃុំក្រាំងញាយ ឃុំជើងរាស់សាមគ្គី ឃុំត្រែងត្រយឹង និងឃុំផុង ព្រមទាំងផ្តល់ការបណ្តុះបណ្តាលផ្នែកសម្ភព ដល់ឆ្មបចំនួន ៣៥នាក់ ដែលមកពីមណ្ឌលផ្តល់សេវាសុខភាពចំនួន៨ក្នុងខេត្តផងដែរ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ ១៩៩១មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៥១.៣ លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥១៣គម្រោងនៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣១០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*